ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា


**ប្រធានគណៈមេធាវី**

មេធាវី លី ច័ន្ទតុលា

**ក្រុមប្រឹក្សាគណៈមេធាវី**

១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ងួនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខូវ ចន្ថា
១២-មេធាវី ហុង គីមសួន
១៣-មេធាវី ឱុយ សុខសូលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណ:
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុគា
១៩-មេធាវី ណុប គុណថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឱម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្ត្រ
២៧-មេធាវី គាន តារា
២៨-មេធាវី ហ៊ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី ទួន ផានិត
៣៣-មេធាវី យុត កែវសុគ្គា


លេខ ២៨៥ /សសគម/២១

# សេចក្តីសម្រេច
# ស្តីពីការបង្កើតក្រុមតេឡេក្រាមផ្លូវការ
# របស់សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **លី ច័ន្ទតុលា** ជាប្រធានគណៈមេធាវីអាណត្តិទី១៣
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវីគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១. គោលបំណង

ត្រូវបានបង្កើតក្រុមតេឡេក្រាមផ្លូវការ របស់សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានឈ្មោះផ្លូវការថា **"សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC)"** និងមានរូបសញ្ញារបស់គណៈមេធាវីជាសម្គាល់ ក្នុងគោលបំណងបង្កើននូវប្រសិទ្ធភាពនៃការគ្រប់គ្រង ការប្រមូលផ្តុំសមាជិក-សមាជិកាតាមប្រព័ន្ធទំនាក់ទំនងបែបបច្ចេកវិទ្យាសម័យទំនើប ដើម្បីចែករំលែកព័ត៌មានវិជ្ជាជីវៈ ការជូនដំណឹង និងការឆ្លើយតបរាល់បញ្ហារបស់សហភាគា ប្រកបដោយភាពឆាប់រហ័ស។




អគារកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ: ១៥៨៧, ទូរស័ព្ទ: ០២៣ ៦២២ ៧០៧០, Building at Corner of Street 1129 and 1930, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh. P.O. Box 1587, Tel: 023 622 70 70 Email: info@bakc.org.kh / Website: www.bakc.org.kh

**ប្រការ ២.. វិសាលភាព**

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះសហភាតាទាំងអស់ដែលបានចុះបញ្ជីជា មេធាវីកំពុងប្រកបវិជ្ជាជីវៈ មេធាវីសុំមិនប្រកបវិជ្ជាជីវៈ មេធាវីកម្មសិក្សា មេធាវីសុំព្យួរកម្មសិក្សា និងមេធាវីសុំនៅក្រៅបញ្ជី ស្របតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

## ជំពូកទី ២
## ការគ្រប់គ្រងក្រុមតេឡេក្រាម

**ប្រការ ៣.. គណៈគ្រប់គ្រងក្រុមតេឡេក្រាម**

គណៈគ្រប់គ្រងក្រុមតេឡេក្រាមមានសមាសភាពដូចខាងក្រោម៖

- ប្រធានគណៈមេធាវី
- អគ្គលេខាធិការ និងអគ្គលេខាធិការរង
- ប្រធាន និងអនុប្រធាននាយកដ្ឋានអធិការកិច្ច
- ប្រធាន និងអនុប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ
- និង ប្រធាន និងអនុប្រធាននាយកដ្ឋានបុគ្គលិកនិងរដ្ឋបាល។

**ប្រការ ៤.. តួនាទីភារកិច្ចនៃគណៈគ្រប់គ្រងក្រុមតេឡេក្រាម**

គណៈគ្រប់គ្រងក្រុមតេឡេក្រាមមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជូនដំណឹងដល់សមាជិក-សមាជិកាទាំងអស់ ក្នុងការផ្តល់ព័ត៌មានអំពីលេខទូរស័ព្ទផ្ទាល់ខ្លួនដែលភ្ជាប់ជាមួយកម្មវិធីតេឡេក្រាម
- ផ្តល់ការណែនាំអំពីការទាញយកកម្មវិធី ការចុះឈ្មោះ ការប្រើប្រាស់ និងការអនុលោមបទបញ្ជាក្រុម
- ពិនិត្យ និងសម្រេច ការដកសមាជិកភាពពីក្នុងក្រុមតេឡេក្រាម ដោយមូលហេតុ ការទទួលមរណៈភាព ការឈប់ប្រកបវិជ្ជាជីវៈមេធាវី ការលុបឈ្មោះចេញពីបញ្ជីគណៈមេធាវី និងការផ្អាកពីមុខងារជាបណ្តោះអាសន្ន
- ធ្វើបច្ចុប្បន្នភាពសមាជិកភាពជាប្រចាំ
- ត្រួតពិនិត្យ និងតាមដានសកម្មភាពរបស់សមាជិកក្នុងក្រុមជាប្រចាំ
- ធ្វើការក្រើនរំលឹក ដាស់តឿន ដល់សមាជិក ដែលបានប្រព្រឹត្តខុសនឹងក្រមសីលធម៌របស់ក្រុម
- ដាក់ពិន័យសមាជិកក្រុមដែលបានប្រព្រឹត្តខុសនឹងក្រមសីលធម៌របស់ក្រុម
- ឆ្លើយតបនូវរាល់បញ្ហា ចម្ងល់ ដោយផ្តល់ជាអនុសាសន៍ដល់សមាជិក-សមាជិកា
- ផ្តល់នូវរាល់ព័ត៌មានផ្លូវការរបស់គណៈមេធាវី
- បំពេញតួនាទី ភារកិច្ចផ្សេងទៀត តាមការចាត់តាំងរបស់ប្រធានគណៈមេធាវី។

## ប្រការ ៥. សកម្មភាពគណៈមេធាវី

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈគណៈគ្រប់គ្រងក្រុមតេឡេក្រាមអាចធ្វើសកម្មភាព ដូចខាងក្រោម៖

- ជូនដំណឹង ឬផ្តល់ព័ត៌មានផ្លូវការ ដល់សមាជិក-សមាជិកាគណៈមេធាវីទាំងអស់ ឬសមាជិកគណៈមេធាវីណាម្នាក់
- ជូនដំណឹង ឬផ្តល់ព័ត៌មានផ្លូវការអំពីសេចក្តីសម្រេច សេចក្តីជូនដំណឹង សេចក្តីថ្លែងការណ៍ សេចក្តីអំពាវនាវ គោលនយោបាយ ឬលិខិតនានា របស់គណៈមេធាវី
- ជូនដំណឹង ឬផ្តល់ព័ត៌មានផ្លូវការអំពីកម្មវិធីសិក្ខាសាលា កម្មវិធីបណ្តុះបណ្តាលផ្សេងៗ ជាអាទិ៍
- ផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់គណៈមេធាវី
- ឆ្លើយតបបន្ទាន់ទៅនឹងបញ្ហា ឬចម្ងល់នានាទាក់ទងនឹងការប្រកបវិជ្ជាជីវៈរបស់សមាជិក-សមាជិកា
- ធ្វើសកម្មភាពផ្សេងៗទៀតដែលចាំបាច់។

## ប្រការ ៦. ក្រុមការងារផ្សេងៗ

ប្រធានគណៈមេធាវីមានសិទ្ធិបង្កើតក្រុមការងារផ្សេងៗតាមការចាំបាច់។

# ជំពូកទី ៣
# ប្រភេទ និងទម្រង់ព័ត៌មានរបស់សមាជិកក្រុមតេឡេក្រាម

## ប្រការ ៧. ប្រភេទនៃព័ត៌មានរបស់សមាជិកក្រុមតេឡេក្រាម

ព័ត៌មានដែលសមាជិកក្រុមអាចលើកយកមកដាក់ក្នុងក្រុមតេឡេក្រាមបាន មានជាអាទិ៍ ការរាយការណ៍ ការស្នើសុំអន្តរាគមន៍ ការចែករំលែក ការលើកយោបល់ទូទៅ ការលើកអំពីបញ្ហាប្រឈម ការលើកនូវចម្ងល់ ការលើកយោបល់សម្រាប់មហាសន្និបាតប្រចាំឆ្នាំ និងការឃោសនាបោះឆ្នោតប្រធានឬក្រុមប្រឹក្សាគណៈមេធាវី។

## ប្រការ ៨. ការរាយការណ៍

សមាជិកក្រុមតេឡេក្រាម អាចធ្វើសេចក្តីរាយការណ៍តាមរយៈក្រុមតេឡេក្រាមនេះ ហើយអាចដាក់ចូលក្នុងក្រុមនូវករណីដូចខាងក្រោម៖

- ភាពមិនប្រក្រតីនៃការប្រកបវិជ្ជាជីវៈ
- ភាពមិនប្រក្រតីនៃការបើកការិយាល័យ ក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី
- ការប្រព្រឹត្តខុសវិធានវិជ្ជាជីវៈមេធាវី
- សកម្មភាពផ្សេងទៀតទាក់ទងនឹងការប្រកបវិជ្ជាជីវៈមេធាវី។

គណៈគ្រប់គ្រងក្រុមតេឡេក្រាមត្រូវចាត់ឲ្យនាយកដ្ឋានអធិការកិច្ចនៃគណៈមេធាវី ចាប់ផ្តើមនីតិវិធីនៃការធ្វើអធិការកិច្ចលើករណីទាំងនោះ រួចដាក់ជូនប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវី ពិនិត្យ និងសម្រេច។

## ប្រការ ៩. ការស្នើសុំអន្តរាគមន៍

សមាជិកក្រុមតេឡេក្រាម អាចស្នើសុំអន្តរាគមន៍តាមរយៈក្រុមតេឡេក្រាមនេះការដាក់ចូលមកក្នុងក្រុមនូវករណីដូចខាងក្រោម៖

- ការស្នើសុំអន្តរាគមន៍ពីប្រធានគណៈមេធាវី ចំពោះមេធាវីដែលទទួលរងបណ្តឹង ត្រូវបានឃាត់ខ្លួន ឬចាប់ខ្លួន ដោយសារការប្រកបវិជ្ជាជីវៈ
- ការស្នើសុំអន្តរាគមន៍ពីប្រធានគណៈមេធាវី ចំពោះមេធាវីដែលត្រូវរងគ្រោះមកលើខ្លួនដោយសារការប្រកបវិជ្ជាជីវៈ
- ការស្នើសុំអន្តរាគមន៍ទៅអាជ្ញាធរមានសមត្ថកិច្ច ក្រសួង ស្ថាប័ន ពាក់ព័ន្ធ ដើម្បីប្រយោជន៍រួមរបស់វិជ្ជាជីវៈមេធាវី
- មេធាវីណាម្នាក់ដែលកំពុងជួបបញ្ហា។

## ប្រការ ១០. ការចែករំលែក បញ្ហាប្រឈម ចម្ងល់ ឬយោបល់ទូទៅ

សមាជិកក្រុមតេឡេក្រាម អាចចែករំលែកនូវព័ត៌មាន ឯកសារ ឬតំណភ្ជាប់ផ្សេងៗ ដែលមានលក្ខណៈជាការផ្តល់ចំណេះដឹង និងបទពិសោធន៍។

សមាជិកក្រុមតេឡេក្រាមអាចលើកអំពីបញ្ហាប្រឈម ចម្ងល់ ឬយោបល់ទូទៅ អំពីច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិ សម្រាប់ជាធាតុចូលដល់គណៈមេធាវីក្នុងការរៀបចំជាសេចក្តីសម្រេច សេចក្តីណែនាំ ការពន្យល់ ឬដំណោះស្រាយ ជូនសមាជិក-សមាជិកាក្នុងការតម្រង់ទិសដល់ការប្រកបវិជ្ជាជីវៈមេធាវីឲ្យបានត្រឹមត្រូវទៅតាមការកំណត់របស់គតិច្បាប់។

## ប្រការ ១១. ការលើកយោបល់សម្រាប់មហាសន្និបាតប្រចាំឆ្នាំ

សមាជិកក្រុមតេឡេក្រាម អាចបញ្ជូនយោបល់ ឬសំណូមពរនានារបស់ខ្លួនសម្រាប់មហាសន្និបាតប្រចាំឆ្នាំបាន តាមការកំណត់របស់គណៈមេធាវី។

## ប្រការ ១២. ការឃោសនាបោះឆ្នោតប្រធាន ឬក្រុមប្រឹក្សាគណៈមេធាវី

សមាជិក-សមាជិកាដែលជាបេក្ខជនឈរឈ្មោះបោះឆ្នោតប្រធាន ឬក្រុមប្រឹក្សាគណៈមេធាវី អាចធ្វើសកម្មភាពឃោសនារបស់ខ្លួននៅក្នុងក្រុមតេឡេក្រាមបាន ដោយអនុលោមតាមបទបញ្ជានៃការឃោសនាបោះឆ្នោត។

សមាជិកក្រុមតេឡេក្រាម ពុំអាចបរិយាយរិះគន់ ឬសម្តែងឆន្ទៈគាំទ្រ ឬមិនគាំទ្រ ចំពោះបេក្ខជនបានឡើយ តែអាចស្នើសុំឱ្យបេក្ខជនណាមួយពន្យល់ ឬបកស្រាយចំពោះគោលនយោបាយរបស់ខ្លួនបាន។

## ជំពូកទី ៤
## បទបញ្ជាផ្ទៃក្នុងរបស់ក្រុមតេឡេក្រាម

### ប្រការ ១៣.- ការរក្សាការសម្ងាត់របស់ក្រុមតេឡេក្រាម

សមាជិក-សមាជិកា មិនត្រូវផ្សព្វផ្សាយ ឬចែករំលែកបន្ត នូវសកម្មភាព ឬព័ត៌មានទាំងឡាយដូចមានចែងក្នុងប្រការ៨ ប្រការ៩ ប្រការ១១ និងប្រការ១២ នៃសេចក្តីសម្រេចនេះ លើកលែងតែមានការអនុញ្ញាតពីប្រធានគណៈមេធាវី។

### ប្រការ ១៤.- សីលធម៌ជាមូលដ្ឋានក្នុងការជជែកពិភាក្សាគ្នា

រាល់ការជជែកពិភាក្សាទាំងឡាយរបស់សមាជិក-សមាជិកា គឺត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ជាមូលដ្ឋានដូចខាងក្រោម៖

- គោរពឋានានុក្រមនៃគណៈមេធាវី ភាពចាស់ទុំនៃវ័យ និងភាពចាស់ទុំក្នុងវិជ្ជាជីវៈ
- គោរពតាមការណែនាំរបស់គណៈគ្រប់គ្រងក្រុមតេឡេក្រាម
- មិនត្រូវប្រើពាក្យពេចន៍ សំណេរ រូបភាព វីដេអូ ឯកសារផ្អែកទន់ ឬការជជែកពិភាក្សាមានលក្ខណៈប្រមាថមើលងាយដល់ ប្រធានគណៈមេធាវី សមាជិកក្រុមប្រឹក្សាគណៈមេធាវី អគ្គលេខាធិការដ្ឋានគណៈមេធាវី គណៈគ្រប់គ្រងក្រុមតេឡេក្រាម និងសមាជិកក្នុងក្រុមតេឡេក្រាម
- មិនត្រូវប្រើពាក្យពេចន៍ សំណេរ រូបភាព វីដេអូ ឬឯកសារផ្អែកទន់បែបអាសអាភាស
- មិនត្រូវប្រើពាក្យពេចន៍អសុរោះ ជេរត្មះ ប្រទេចផ្តាសា។

### ប្រការ ១៥.- ទម្រង់នៃទំនាក់ទំនង

សមាជិកក្រុម អាចទំនាក់ទំនងមកក្នុងក្រុមដោយត្រូវសរសេរជាខេមរភាសា ឬអាចប្រើជារូបភាព វីដេអូ ឬជាឯកសារផ្អែកទន់ សម្រាប់ការជជែកពិភាក្សា និងការដាក់សំណើផ្សេងៗ។

សមាជិកក្រុម ពុំត្រូវប្រើប្រាស់សារជាស្ទីកគ័រ(Stickers) ឬរូបភាពមានចលនា(GIF) ជាមធ្យោបាយនៃការជជែកពិភាក្សាឡើយ។

### ប្រការ ១៦.- ការហាមឃាត់ដាច់ខាត

ពុំអនុញ្ញាតឱ្យសមាជិកក្រុម ធ្វើសកម្មភាព និយាយ សរសេរ សម្តែង វីដេអូ ដាក់រូបភាព ដាក់ឯកសារផ្អែកទន់ ឬការជជែកពិភាក្សា ដូចខាងក្រោម៖

- ប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ក្រសួង ស្ថាប័ន អង្គភាពនានា
- ប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ឥស្សរជន ឬបុគ្គលនយោបាយ ឬមន្ត្រី នៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈនានា
- ប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់ចៅក្រម ឬព្រះរាជអាជ្ញា នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់

- ប្រកាន់និន្នាការនយោបាយ និងការឃោសនាពីគណបក្សនយោបាយ
- ប្រមាថដល់វិជ្ជាជីវៈមេធាវី
- ជជែកដោយកំហឹង
- បង្កជម្លោះ
- លុបក្រុមតេឡេក្រាមចោល
- ដកសមាជិកក្រុមដោយពុំមានការអនុញ្ញាត
- ចាកចេញពីក្រុមដោយពុំមានការអនុញ្ញាត
- បំពានតាមបែបបច្ចេកវិទ្យា (Hack)
- បង្កការរំខាន
- បង្កការញុះញង់
- គំរាមកំហែង
- បង្កើតបញ្ហាផ្សេងៗដែលមិនមានគុណតម្លៃ ឬគុណប្រយោជន៍សម្រាប់សមាជិក។

## ជំពូកទី ៥
## បទវិន័យ

### ប្រការ ១៧. កម្រិតវិន័យ

កម្រិតបទវិន័យរួមមាន៖

- ការក្រើនរំលឹក ដាស់តឿនអំពីការប្រព្រឹត្តកំហុស
- ការដកសិទ្ធិបណ្ដោះអាសន្នក្នុងការរាយការណ៍ ការចែករំលែក ការលើកយោបល់ទូទៅ ការលើកអំពីបញ្ហាប្រឈម ការលើកនូវចម្ងល់ ការលើកយោបល់សម្រាប់មហាសន្និបាតប្រចាំឆ្នាំ និងការឃោសនាបោះឆ្នោតប្រធានឬក្រុមប្រឹក្សាគណៈមេធាវី មិនលើសរយៈពេល ៦(ប្រាំមួយ)ខែ។

### ប្រការ ១៨. ការអនុវត្តបទវិន័យ

សមាជិកក្រុមតេឡេក្រាម ដែលបានប្រព្រឹត្តខុសនឹងប្បញ្ញត្តិនៃប្រការ១៣ ប្រការ១៤ ប្រការ១៥ និងប្រការ១៦ នៃសេចក្ដីសម្រេចនេះ ត្រូវទទួលរងនូវបទវិន័យដូចមានចែងក្នុងប្រការ១៧ ខាងលើ និងទទួលខុសត្រូវចំពោះមុខច្បាប់។ គណៈគ្រប់គ្រងក្រុមតេឡេក្រាម មានសមត្ថកិច្ចផ្ដាច់មុខក្នុងការអនុវត្តបទវិន័យនេះ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

### ប្រការ ១៩. និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ២០.- ការអនុវត្ត**

សេចក្ដីសម្រេចនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១

**ប្រធានគណៈមេធាវី**

មេធាវី លី_ចន្ទតុលា